រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែតុលា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ៧២ សសរ.

## ស្តីពីការនាំពលករកម្ពុជា ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រុមហ៊ុន ហ្យូមេនរីសសស៍ ឌីវេឡុបមេន ខូអិលធីឌី (HUMAN RESOURCES DEVELOPMENT CO.,LDT)
- ដើម្បីធានាប្រសិទ្ធភាព នៃការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការនាំពលករចេញទៅបរទេស

## សំរេច

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន ហ្យូមេនរីសសស៍ ឌីវេឡុបមេន ខូអិលធីឌី (HUMAN RESOURCES DEVELOPMENT CO.,LDT) ធ្វើការផ្តាច់មុខក្នុងការនាំពលករទៅធ្វើការនៅប្រទេសម៉ាឡេស៊ី លើកលែងតែផ្នែកបំរើការងារក្នុងផ្ទះ (Housemaid) ដែលក្រុមហ៊ុនបាន ដំណើរការខ្លះៗមកហើយ ។

**ប្រការ ២ :** ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវចុះកិច្ចសន្យា និងចេញអាជ្ញាប័ណ្ណឲ្យក្រុមហ៊ុននេះ អនុវត្តតាមខ្លឹមសារ ដូចមានចែងក្នុងប្រការ ១ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងក្រុមហ៊ុន ហ្យូមេនរីសសស៍ ឌីវេឡុបមេន ខូអិលធីឌី (HUMAN RESOURCES DEVELOPMENT CO.,LDT) ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន